ហ្វ្រេដចិន ភីកលីស៊ុមី ឃីននី
( ផ្អែកទៅលើដំណើររឿងពិត )

*រឿងនេះបានកើតឡើងនៅក្នុងប្រទេសកាណាដា ។*

ដាយជី ចង់ស្ដាប់សន្និសីទទូទៅ ។ គាត់ព្យាយាមអង្គុយស្ងៀម ។ គាត់ព្យាយាមស្ដាប់សុន្ទរកថាទាំងឡាយ ។ ប៉ុន្តែជំងឺអូទីស្សឹមធ្វើឲ្យគាត់ពិបាកផ្ដោតអារម្មណ៍ណាស់ ។ គាត់នៅមិនស្ងៀមនៅលើសាឡុងឡើយ ។ គាត់លេងប្រដាប់លេងរបស់គាត់ ។ គាត់រត់ចុះឡើង ។

បន្ទាប់មកគាត់មើលទៅប៉ា ។ ប៉ាអង្គុយយ៉ាងស្ងៀមស្ងាត់ ហើយស្ដាប់អ្នកឡើងនិយាយ ។ ដាយជី ចង់ធ្វើដូចប៉ា ។ អ៊ីចឹង គាត់ក៏យកប្រដាប់ប្រដាគូររូបគាត់មក ។ ប្រហែលជាការផាត់ពណ៌រូបភាពធ្វើឲ្យគាត់អង្គុយស្ងៀមបាន ។

ខណៈពេលគាត់បានផាត់ពណ៌ ដាយជី បានស្ដាប់អែលឌើរ ដែហ្វ្រី អ័រ ហូឡិន មានប្រសាសន៍ ។ អែលឌើរ ហូឡិន បានប្រាប់ដំណើររឿងអំពីព្រះយេស៊ូវ ។ ព្រះយេស៊ូវបានបង្គាប់ឲ្យកំលោះអ្នកមានចែកប្រាក់របស់គាត់ទៅដល់ជនក្រីក្រ ។*

ដាយជី ក៏ចង់ជួយដល់ជនដែលគ្មានប្រាក់គ្រប់គ្រាន់ផងដែរ ។ ហើយគាត់មានគំនិតមួយ ។

ដាយជី បាននិយាយថា « ម៉ាក់ កូនចង់គូររូបសត្វទីទុយ » ។ « តើម៉ាក់គូរឲ្យកូនមួយបានទេ ? »

ម៉ាក់បានតបថា « បានតើកូន » ។ នាងបានគូររូបសត្វទីទុយមួយ ។

*តើរូបគំនូររបស់ ដាយជី ជួយអ្នកដទៃដោយរបៀបណា ?*



# សត្វទីទុយ និងសត្វអ័រកា

ដាយជី បានជ្រលក់ជក់របស់គាត់ទៅក្នុងទឹកថ្នាំ ។ គាត់បានគូរស្លាបរបស់សត្វទីទុយមុន ។ គាត់បានគូររោមពណ៌ត្នោតខ្លះ។ ហើយស្លាបខ្លះទៀតមានពណ៌ទឹកក្រូច ។ នៅពេលដែលគាត់គូររូប គាត់បានស្ដាប់សុន្ទរកថាផ្សេងទៀត ។ ទោះជាសុន្ទរកថាទាំងអស់បានបញ្ចប់ហើយក៏ដោយក៏ដាយជី នៅតែបន្តគូររូបដែរ ។ គាត់ចង់ឲ្យសត្វទីទុយមើលទៅស្អាតឥតខ្ចោះ ។

នៅទីបំផុត ដាយជី បានគូររូបហើយ ។ គាត់បានបង្ហាញរូបទីទុយនោះទៅម៉ាក់របស់គាត់ ។

« វាស្អាតណាស់ ! » ម៉ាក់បាននិយាយ ។ « តើយើងគួរតែដាក់វាព្យួរទេ ? »

ដាយជី បានគ្រវីក្បាលថាទេ « កូនចង់យករូបនេះទៅលក់ ហើយយកលុយទៅជួយជនដែលខ្វះខាតលុយ ។ ដូចអ្វីដែលពួកលោកបាននិយាយនៅក្នុងសន្និសីទ » ។

ម៉ាក់ បានញញឹម ។ « ចាំមើល ថាតើយើងអាចធ្វើអ្វីបាន » ។

នាងបានចុះផ្សាយរូបគំនូររបស់ ដាយជី លក់នៅតាមអនឡាញ ។ ម៉ាក់បានសរសេរថា ដាយជី នឹងយកលុយនោះទៅបរិច្ចាគដល់អ្នកគ្មានផ្ទះសម្បែង ។

នៅថ្ងៃស្អែក ដាយជី និងម៉ាក់បានមើលការចុះផ្សាយនោះ ។ ដាយជី មិនចង់ជឿឡើយ ! មនុស្សជាច្រើនចង់ទិញរូបគំនូររបស់គាត់ ។ គាត់សប្បាយចិត្តដែលមានមនុស្សជាច្រើនចង់ជួយ ។

ភោជនីយដ្ឋានមួយនៅទីក្រុងរបស់ដាយជី បានសុំទិញរូបគំនូរនេះ ។ ពួកគេនិយាយថា ពួកគេឲ្យថ្លៃដល់ ១០ ដងពីតម្លៃដែល ដាយជី និងម៉ាក់របស់គាត់បានសុំ ! ហាងផ្សេងទៀតក៏បានសុំឲ្យគាត់គូររូបផងដែរ ។ ដាយជី បានមានការងារធ្វើច្រើន !

ម៉ាក់បានដានរូបសត្វជាច្រើនទៀត ហើយដាយជី បានយកប្រដាប់ផាត់ពណ៌របស់គាត់មក ។ គាត់បានផាត់ពណ៌ឆ្កែចចក គោ និង អ័រកា ។ គាត់ចូលចិត្តអ័រកាខ្លាំងណាស់ ។ គាត់បានដាក់ឈ្មោះឲ្យវាថា « អ័រកា អូទីស » ។ ហាងលក់គ្រឿងទេសនៅជិតផ្ទះគាត់បានទិញរូបគំនូរនេះ ។ នៅពេល ដាយជី បានទៅហាងនៅថ្ងៃបន្ទាប់ គាត់បានឃើញរូបគំនូរនោះដាក់តាំងនៅលើជញ្ជាំង ។

« ម៉ាក់ មើលហ្ន៎ ! » ដាយជី បានចង្អុលទៅរូបគំនូរ ។



« អស្ចារ្យណាស់ ! » ម៉ាក់បាននិយាយ ។ « ឥឡូវនេះនៅពេលយើងមកទីនេះយើងអាចនឹកឃើញពីទេព្យកោសល្យរបស់កូនដែលបានជួយមនុស្សទូទៅ » ។

ដាយជី មានមោទនភាពដែលមានគេចូលចិត្តរូបគំនូររបស់គាត់ ។ ប៉ុន្តែគាត់កាន់តែសប្បាយចិត្តដែលគាត់អាចជួយអ្នកដទៃបាន ។ គាត់សប្បាយចិត្តដែលគាត់បានស្ដាប់ក្នុងអំឡុងពេលសន្និសីទទូទៅ ។ ●

* *មកពី « ទ្រព្យសម្បត្តិច្រើនណាស់ »* លីអាហូណា *ខែ វិច្ឆិកា ឆ្នាំ ២០២១ ទំព័រ ៨–១០ ។*



ដាយជី បានគូរគំនូរលក់ដោយសារគាត់ចង់ជួយមនុស្ស ។ តើប្អូនអាចជួយអ្នកដទៃបានយ៉ាងដូចម្ដេច ?